**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរនៅតាមផ្លូវជាតិលេខ១
## ចំណុចភូមិលៀប ឃុំកណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង
## ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីរន្ធត់ និងសោកស្តាយយ៉ាងក្រៃលែង នៅពេលបានទទួលដំណឹងថា មានឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរក្រឡាប់រថយន្តដឹកកម្មករ កាលពីវេលាម៉ោង១៧និង៥០ នាទីល្ងាច ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ ស្ថិតនៅតាមផ្លូវជាតិលេខ១ ចន្លោះគីឡូម៉ែត្រលេខ១៣៩ និង១៤០ ចំណុចភូមិលៀប ឃុំកណ្តៀងរាយ ស្រុកស្វាយទាប ខេត្តស្វាយរៀង ដែលបានបណ្តាលឱ្យកម្មករបម្រើការងារនៅរោងចក្រនីស៊ី (ខេមបូឌា) ក្នុងតំបន់សេដ្ឋកិច្ចពិសេសនាគរាជ ស្ថិតនៅភូមិព្រៃទប់ សង្កាត់ព្រៃអង្គុញ ក្រុងបាវិត ខេត្តស្វាយរៀង រងរបួសធ្ងន់ស្រាលចំនួន៦៩នាក់ និងជនរងគ្រោះ ២នាក់ទៀត បាត់បង់ជីវិត។ អ្នករងរបួសទាំងនេះ បានទទួលការជួយសង្គ្រោះពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច និងមន្ត្រីបេឡាជាតិរបបសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយយកចិត្តទុកដាក់បំផុត។ ដោយឡែក សពជនរងគ្រោះទាំង២នាក់ត្រូវបានក្រុមគ្រួសារយកទៅធ្វើបុណ្យតាមប្រពៃណី។ គិតត្រឹមម៉ោង៩:៣០នាទីព្រឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ នេះ កម្មករចំនួន៦៩នាក់ដែលរងរបួស បាននឹងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែកជីភូ ចំនួន៥២នាក់ មន្ទីរពេទ្យបង្អែកស្រុកស្វាយទាប ចំនួន៥នាក់ និងមន្ទីរពេទ្យបង្អែកខេត្តស្វាយរៀង ចំនួន១២នាក់។

ឆ្លៀតក្នុងឱកាសដ៏ក្រៀមក្រំនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមចូលរួមរំលែកនូវសេចក្តីសោកស្តាយចំពោះគ្រួសារសព និងអាណិតស្រឡាញ់ជាទីបំផុតជាមួយក្រុមគ្រួសារ និងញាតិមិត្តទាំងអស់របស់ជនរងគ្រោះ ហើយជូនពរឱ្យអ្នកដែលរងរបួសឆាប់បានជាសះស្បើយ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងបន្តជួយដោះស្រាយទុក្ខលំបាករបស់បងប្អូនកម្មករ កម្មការិនី និងក្រុមគ្រួសារទៅតាមគោលរបបសន្តិសុខសង្គមរបស់បេឡាជាតិរបបសន្តិសុខសង្គម។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦



Scanned by CamScanner